AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

# របាំប្រពៃណីខ្មែរ

ព្រះរាជាណាចក្រកម្ពុជា ប្រកបដោយវប្បធម៌អរិយធម៌រុងរឿង ទម្រង់សិល្បៈ សម្បូណ៌បែប មានចម្រៀង តន្ត្រី ល្ខោន របាំប្រជាប្រិយ របាំព្រះរាជទ្រព្យនាសម័យបុរាណ គ្រប់គ្រងនិងទំនុកបម្រុងដោយព្រះមហាក្សត្រ និងរបាំប្រពៃណីនៅជាប់ជាមួយនឹងប្រជារាស្ត្រ ជាពិសេសអ្នករស់នៅតាមជនបទស្រុកស្រែចម្ការ ក្នុងតំបន់ខ្ពង់រាបនិងតំបន់ភ្នំ តាមដងទន្លេ និងសមុទ្រ។ របាំប្រពៃណីមានដើមកំណើតកើតឡើងពី ជំនឿ សាសនា ទំនៀមទម្លាប់ ប្រពៃណី ពិធី និងការកែកម្សាន្ត។

ជនជាតិដើមភាគតិចនៅកម្ពុជា ក៏មានរបាំប្រពៃណីជនជាតិប្រចាំជាតិសាសន៍របស់ខ្លួន ដូចជា របាំកាប់ក្របី របស់ជនជាតិដើមភាគតិចគ្រឹង ទំពួន និងព្នងក្នុងខេត្តរតនគិរីនិងមណ្ឌលគិរី ពាក់ព័ន្ធនឹងពិធីកាប់ក្របី សែនព្រេន លៀងអារក្ស និងផឹកស្រាក្នុងជំនឿអរូបី គោរពព្រលឹង អារក្ស អ្នកតា។ របាំព្យួយសួយ របស់ជនជាតិសួយខេត្តកំពង់ស្ពឺ។ របាំវាយគួយ ប្រវាយគួយ ឬវាយខែល ពាក់ព័ន្ធនឹងកីឡានិងលំហាត់កាយសម្បទារបស់ជនជាតិគួយខេត្តកំពង់ធំ។ របាំស្នែងទន្សោង របាំសែនព្យួយ របាំក្ងោកពោធិសាត់ និងរបាំបេះក្រវាញ របស់ជនជាតិព័ររស់នៅក្នុងតំបន់ភ្នំក្រវាញ ខេត្តពោធិសាត់។ របាំចាមនិងរបាំកំចាត់ឧបទ្រពចង្រៃ របស់ជនជាតិខ្មែរអ៊ីស្លាមខេត្តកំពង់ឆ្នាំង។ របាំក្ងោកប៉ៃលិន របស់ជនជាតិកូឡាខេត្តប៉ៃលិន។ល។

ពាក់ព័ន្ធនឹងប្រពៃណីនិងសាសនា ប្រជាពលរដ្ឋខេត្តសៀមរាបសម្តែង របាំត្រុដិ នៅពេលចូលឆ្នាំខ្មែរត្រស្តិសង្ក្រាន្ត ដើម្បីកាត់ផ្តាច់ឆ្នាំចាស់និងអបអរសាទរទទួលនិងចូលឆ្នាំថ្មីនាំមកនូវសុភមង្គលសិរីសួស្តី។ របាំប្រពៃណីមួយចំនួនពាក់ព័ន្ធនឹងធម្មជាតិស្រុកខ្មែរ កសិកម្ម ការកែកម្សាន្ត និងជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរអ្នកស្រែចម្ការដូចជា របាំគោះត្រឡោក របាំក្រាប់ របាំនេសាទ របាំគោះអង្រែ។ល។ ពាក់ព័ន្ធនឹងប្រពៃណី មានរបាំបុកល័ក្ត សម្តែងនៅក្នុងពិធីអាពាហ៍ពិពាហ៍។

អត្ថបទដោយ៖

## អត្ថបទ៖ របាំប្រពៃណីខ្មែរ

សោភ័ណរបស់របាំក្បាច់បុរាណឬរបាំព្រះរាជទ្រព្យ ស្ថិតនៅលើក្បាច់និងភាសាក្បាច់ រាប់ពាន់ សម្លៀកបំពាក់ និងគ្រឿងអលង្ការ។ ចំណែកឯរបាំប្រពៃណី គឺស្ថិតនៅលើក្រឡា របាំ កាយវិការ និងអត្ថន័យខ្លឹមសារសាមញ្ញងាយយល់។

របាំប្រពៃណីខ្មែរកំដរដោយវង់តន្ត្រីមហោរី។ ដោយឡែក របាំមួយចំនួនកំដរដោយវង់តន្ត្រីដែលរបាំតម្រូវការ ដូចជារបាំទន្សោង របាំត្រោកពោធិសាត់ របាំត្រោកប៉ៃលិន ឬរបាំត្រុដិ ជាដើម។ របាំប្រពៃណីខ្មែរ សម្ដែងនៅក្នុងបរិបទកំដរពិធីតម្រូវការ តែជាទូទៅគឺនៅក្នុងបរិយាកាសសប្បាយរីករាយក្រោយពេលច្រូតកាត់រួច ការជួបជុំគ្នា ឬនៅក្នុងកម្មវិធីសម្ដែងសិល្បៈផ្សេងៗ។

របាំប្រពៃណី ជា «កញ្ចក់ឆ្លុះសង្គម» ពោលគឺលាតត្រដាងឆ្លុះបង្ហាញអំពីជីវិតរស់នៅរបស់ប្រជាពលរដ្ឋខ្មែរនិងជនជាតិស្រុកខ្មែរ មានជំនឿ សាសនា ទំនៀមទម្លាប់ ប្រពៃណី ធម្មជាតិ ជីវិត និងសកម្មភាពកសិកម្មរបស់ខ្មែរ។

### ឯកសារយោង


ពេជ្រ ទុំក្រវិល

២០០១. *របាំខ្មែរ*. ភ្នំពេញ: អង្គការមូលនិធិតូយ៉ូតា។

Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang.

1988. *Khmer Folk Dance*, (2nd ed.). Washington, DC: Cambodian Network Council.

# បញ្ជីរូបភាព





អត្ថបទដោយ៖





អត្ថបទដោយ៖